**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃ អាទិត្យ ៥ រោច ខែ កត្តិក ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២២

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃពិព័រណ៍បច្ចេកវិទ្យាកម្ពុជា ២០២២

ក្នុងពិព័រណ៍បច្ចេកវិទ្យាកម្ពុជា ២០២២ ដែលប្រព្រឹត្តឡើងនា**ថ្ងៃទី ១១ ដល់ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២២ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ធនាគារជាតិនៃកម្ពុជា មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និង CamTech Summit ដែលគាំទ្រដោយក្រុមហ៊ុនព្រូដិនសលកម្ពុជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា បានសហការរៀបចំវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលជាពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុលើកដំបូងនៅកម្ពុជា។ វេទិកានេះមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានអប់រំ ស្ថាប័នស្រាវជ្រាវ ដៃគូអភិវឌ្ឍន៍ ព្រមទាំងសមាគម និងស្ថាប័នពាក់ព័ន្ធដទៃក្នុងវិស័យឯកជន សរុបប្រមាណ **៣៩០ រូប**។

វេទិកានេះមានគោលបំណងគាំទ្រ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និងបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា ដោយកៀរគរនិយ័តករ វិស័យឯកជន ក៏ដូចជាស្ថាប័នជាតិនិងអន្តរជាតិពាក់ព័ន្ធ មកជួបជុំគ្នា ស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់ពីនិន្នាការនិងនវានុវត្តន៍ឬផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងពិភាក្សាពីកាលានុវត្តភាព និងបញ្ហាប្រឈមនានា ដើម្បីពង្រឹងនិងពង្រីកប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្តោបយកឱកាសជាអតិបរមាពីនវានុវត្តន៍ទាំងនោះ ព្រមទាំងសម្រប និងត្រៀមខ្លួនសម្រាប់ការវិវឌ្ឍដ៏រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា។ គោលបំណងសំខាន់មួយទៀតរបស់វេទិកានេះគឺ ការបន្តប្រមូលធាតុចូលល្អៗ និងជាក់លាក់បន្ថែមក្នុងដំណើរការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ដែលមានលក្ខណៈមុតស្រួចនិងងាយបត់បែន។

វេទិកានេះចាប់ផ្តើមដោយសុន្ទរកថាស្វាគមន៍របស់ថ្នាក់ដឹកនាំកិត្តិយសមួយចំនួនរួមមាន **លោក** Remi Pell ប្រធានសមាគមហិរញ្ញវត្ថុនិងបច្ចេកវិទ្យាកម្ពុជា, **លោក សុខ វឿន** ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា, **លោក** Raymond Sia Say Guan ប្រធានសមាគមធនាគារនៅកម្ពុជា, **លោក** Sanjay Chakrabarty នាយកប្រតិបត្តិនៃក្រុមហ៊ុនព្រូដិនសលកម្ពុជា និង **ឯកឧត្តម អ៊ូ ចាន់តារា** ឧបការីទេសាភិបាលនិងជាអគ្គលេខាធិការនៃធនាគារជាតិនៃកម្ពុជា។ វេទិកានេះទទួលបានការអញ្ជើញចូលរួមដ៏ខ្ពង់ខ្ពស់ក្នុងការប្រកាសបើកដំណើរការជាផ្លូវការដោយ **ឯកឧត្តម វង្សី វិស្សុត**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ **ឯកឧត្តម** បានថ្លែងពីទិដ្ឋភាពសំខាន់ៗដែលបញ្ជាក់កាន់តែច្បាស់ពីសក្តានុពលដ៏ខ្ពស់របស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការជំរុញសេដ្ឋកិច្ចជាតិ តំបន់ និងសកល ស្របពេលដែលសម្ពុះឧស្សាហកម្មហិរញ្ញវត្ថុកម្ពុជា ទាំងវិស័យធនាគារ និងមិនមែនធនាគារ សម្រេចបានកំណើនខ្លាំងក្លា ជាមួយនឹងការលេចឡើងនូវបច្ចេកវិទ្យាថ្មីៗ ដូចជា Blockchain ឬ Distributed Ledger ជាដើម។ **ឯកឧត្តម** បានបន្តដែរថា *"ស្ថាប័នហិរញ្ញវត្ថុណាដែលចាប់យក និងប្រើបច្ចេកវិទ្យាហិរញ្ញវត្ថុបានលឿន និងមុនគេ ពិតជាអាចប្រែក្លាយវិបត្តិឱ្យទៅជាឱកាសថ្មីក្នុងការពង្រឹង និងពង្រីកសេវារបស់ខ្លួនកាន់តែខ្លាំង និងមានភាពធន់ខ្ពស់ក្នុងការឆ្លើយតបទៅនឹងវិបត្តិនេះ។"* ជាមួយគ្នានេះ **ឯកឧត្តម** ក៏បានលើកឡើងពីការចូលរួមយ៉ាងសស្រាក់សស្រាំរបស់រាជរដ្ឋាភិបាលតាមរយៈគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

ក្នុងរយៈពេលបីថ្ងៃនៃវេទិកានេះ មានបទបង្ហាញចំនួន ១២ ដែលផ្តោតលើប្រធានបទសំខាន់ៗដូចជា ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជានិងអាស៊ាន, សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, ឌីជីថលូបនីយកម្មនៃសេវាធនាគារ, ខេ អេច យ្យូ អរ (KHQR) និងបាគង (Bakong), Open Banking, បច្ចេកវិទ្យាធានារ៉ាប់រង, សន្តិសុខសាយប័រក្នុងប្រទេសកំពុងអភិវឌ្ឍន៍, ការដាក់ដំណើរការថ្នាល Cambodia Distributed Ledger (CamDL), និងការយល់ដឹងពី Web 3.0។ ក្រៅពីនេះ វេទិកាក៏មានកិច្ចពិភាក្សាចំនួន ៥ ដែលជជែកលើចលនាបច្ចេកវិទ្យាហិរញ្ញវត្ថុមួយប្រចាំអាស៊ាន, ឌីជីថលូបនីយកម្មក្នុងវិស័យធនាគារនិងធនធានមនុស្ស, សក្តានុពលនៃបច្ចេកវិទ្យាធានារ៉ាប់រង, ការគំរាមកំហែងសាយប័រក្នុងទីផ្សារហិរញ្ញវត្ថុ, និងការកសាងសេវាហិរញ្ញវត្ថុថ្មីតាមរយៈ Web 3.0។

ជាកិច្ចបញ្ចប់នៃវេទិកានេះ បន្ទាប់ពី **លោកស្រី ឃួន ហ្វេងដារា** ហិរញ្ញិកក្រុមប្រឹក្សាភិបាលនៃសមាគមហិរញ្ញវត្ថុនិងបច្ចេកវិទ្យាកម្ពុជា បានថ្លែងសុន្ទរកថាពីការអង្កេតជារួមលើវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុទាំងបីថ្ងៃរួច, **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល បានថ្លែងសុន្ទរកថាបិទដែលក្នុងនោះ **ឯកឧត្តមបណ្ឌិត** បានគូសរំលេចបន្ថែមលើចំណុចមួយចំនួន ដែលរួមបញ្ចូលទាំង បរិការណ៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងកម្ពុជានិងតំបន់អាស៊ាន វិស័យធនាគារនិងធានារ៉ាប់រងនៅកម្ពុជា និងការរៀបចំដាក់ដំណើរការនូវថ្នាលឌីជីថលគន្លឹះ Cambodian Distributed Ledger (CamDL) ជាដើម។ មិនតែប៉ុណ្ណោះ **ឯកឧត្តមបណ្ឌិត** បានផ្តល់នូវការគិតគូរពិចារណាជាសកម្មភាពដល់តួអង្គពាក់ព័ន្ធក្នុងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុផងដែរ។ *"ក្រសួង-ស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ ធុរកិច្ចថ្មី និងសមាគមនានា សូមគិតគូរពិចារណាលើចំណុចពាក់ព័ន្ធសំខាន់ៗចំនួន ៣ គឺ (១) កសាងចលនាឧស្សាហកម្មហិរញ្ញវត្ថុជុំវិញបច្ចេកវិទ្យាដែលនាំទៅការផ្លាស់ប្តូរអតិបរមា, (២) ជំរុញនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការកសាងទីផ្សារមួយដែលសក្តិសមនឹងនវានុវត្តន៍ទាំងនោះ, ព្រមទាំង (៣) កសាងគោលការណ៍សមភាពរវាងក្រុមហ៊ុនធំ និងធុរកិច្ចថ្មី ឬអាជីវកម្មធុនតូច។"* នេះបើតាមប្រសាសន៍របស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី**។

ជាលទ្ធផល វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុបានប្រព្រឹត្តទៅយ៉ាងរលូន បញ្ចប់ដោយភាពជោគជ័យ និងទទួលបានលទ្ធផលគាប់ប្រសើរដូចការរំពឹងទុក ដោយមានអន្តរសកម្ម និងការពិភាក្សាគ្នាយ៉ាងផុសផុល ប្រកបដោយស្មារតីចែករំលែក និងយកចិត្តទុកដាក់ខ្ពស់។ ក្នុងនោះ គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ក៏ប្រមូលធាតុចូលល្អៗបន្ថែម ដែលអាចបន្តជាមូលដ្ឋានដល់ការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាឱ្យកាន់តែគ្រប់ជ្រុងជ្រោយស្របតាមបរិបទក្នុងប្រទេស។